ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ៣៧៣.សកបយ.

ភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០០០

# ប្រកាស

## ស្តីពី

## តួនាទីភារកិច្ចរបស់ប្រតិភូបុគ្គលិក និងសហជីព

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

**ប្រការ១ :** ប្រតិភូបុគ្គលិកគឺជាតំណាង របស់កម្មករ និយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថាន ស្របទៅតាមជំពូកទី ១១ ផ្នែក ទី៣ នៃច្បាប់ស្តីពីការងារ ។

**ប្រការ២ :** សហជីពជាអង្គការវិជ្ជាជីវៈរបស់កម្មករ និយោជិត ស្របទៅតាមមាត្រា ២៦៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៣ :** ប្រតិភូបុគ្គលិកមានបេសកកម្មដូចមានចែងក្នុងមាត្រា ២៨៤ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៤ :** តំណាងសហជីពក៏អាចផ្តល់ពត៌មាន និងសំណើបានដែរចំពោះនិយោជក អំពីបញ្ហាដូចមានចែងក្នុងមាត្រា ៣ ខាងលើ បើសិនជាបញ្ហានោះមានការទាក់ទងចំពោះសមាជិករបស់ខ្លួន ។

**ប្រការ៥ :** ប្រតិភូបុគ្គលិកត្រូវបានគេពិគ្រោះពិភាក្សា និងត្រូវផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដូចចែងក្នុងមាត្រា ២៨៤ កថាខ័ណ្ឌពីរចុងក្រោយ នៃច្បាប់ស្តីពីការងារ ។៤

**ប្រការ៦** : តំណាងសហជីពត្រូវបានគេពិគ្រោះពិភាក្សា និងត្រូវផ្តល់យោបល់ជាលាយលក្ខអក្សរផងដែរ ទៅលើបញ្ហាដែលមានចែង ក្នុងប្រការ ៥ ខាងលើ ។

**ប្រការ៧** : អ្នកដឹកនាំសហជីពសំខាន់បីរូបនៅក្នុងសហគ្រាស គ្រឹះស្ថាន តាមធម្មតារួមមាន ប្រធាន អនុប្រធានទី១ និង លេខាធិការទី១ ដែលបានចុះបញ្ជិកានៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវទទួលបានការការពារ ពីការបញ្ឈប់ពីការងារ ដូចប្រតិភូបុគ្គលិកដែរ ។

**ប្រការ៨** : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អ៊ិត សំហេង

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក "ដើម្បីអនុវត្ត"

-សហព័ន្ធសហជីព "ដើម្បីអនុវត្ត"

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"

-រាជកិច្ច

-កាលប្បវត្តិ និងឯកសារ